# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ០០៣/០៧ គ.ជ.ប

## សេចក្ដីណែនាំ
## ស្ដីពី
## ការពិនិត្យបញ្ជីឈ្មោះបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំដល់ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) និង គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ទាំងអស់ អំពីគោលការណ៍មួយចំនួនស្ដីពីការពិនិត្យបញ្ជីឈ្មោះបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដូចខាងក្រោម :

១. បញ្ជីឈ្មោះបេក្ខជននៃគណបក្សនយោបាយណាមួយដែលក្នុងនោះបេក្ខជនបានបញ្ជាក់យល់ព្រមតាមការតែងតាំងរបស់គណបក្សនយោបាយ និង ដែលត្រូវបានដាក់នៅ គឃ/សប រួចហើយ មិនអាចកែប្រែបានទេ រហូតដល់ពេលបិទផ្សាយបញ្ជីដំបូង ។

២. បេក្ខជនម្នាក់អាចឈរឈ្មោះជាបេក្ខជនបានតែមួយកន្លែងប៉ុណ្ណោះក្នុងឃុំ សង្កាត់ ដែលខ្លួនបានចុះឈ្មោះ និង មានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ។ បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។ គឃ/សប ត្រូវពិនិត្យ និង ផ្ទៀងផ្ទាត់លើបញ្ជីបេក្ខជនរបស់គណបក្សនយោបាយនីមួយៗ ជាមួយនឹងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដទៃទៀតឱ្យបានសុក្រឹតបំផុត ជាពិសេសពិនិត្យលើអត្តសញ្ញាណរបស់បេក្ខជនម្នាក់ៗ ដើម្បីជៀសវាងការឈរឈ្មោះលើសពីមួយគណបក្ស ។

២.១ ករណីពិនិត្យឃើញថា មានបេក្ខជនឈរឈ្មោះលើសពីមួយគណបក្ស គឃ/សប ត្រូវអញ្ជើញតំណាងគណបក្សនយោបាយពាក់ព័ន្ធនឹងបញ្ជីបេក្ខជន និង បេក្ខជនឈរឈ្មោះនោះ មកធ្វើការសម្រេចនៅចំពោះមុខ គឃ/សប ដោយធ្វើកំណត់ហេតុ និង ផ្ដិតមេដៃតំណាងគណបក្សនយោបាយ និង បេក្ខជនផង ។

២.២ ករណីបេក្ខជននោះ មិនព្រមសម្រេចយកគណបក្សនយោបាយណាមួយនោះ គឃ/សប ត្រូវលុបឈ្មោះបេក្ខជននោះចេញ ហើយឱ្យគណបក្សនយោបាយពាក់ព័ន្ធកែតម្រូវឡើងវិញ ។

៣. ករណី គឃ/សប ពិនិត្យឃើញថា បេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ មិនបានចុះឈ្មោះ និង មានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់នោះទេ គឃ/សប ត្រូវលុបឈ្មោះបេក្ខជននោះចេញ ហើយឱ្យគណបក្សនយោបាយធ្វើការកែតម្រូវឡើងវិញ ។

៤. គណបក្សនយោបាយ ដែលមិនទាន់បានបំពេញលក្ខខណ្ឌលិខិតបញ្ជាក់ការចុះឈ្មោះ និង មានឈ្មោះក្នុងបញ្ជីបោះឆ្នោត គឃ/សប ត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ចេញលិខិតបញ្ជាក់នេះ ជូនបេក្ខជនឱ្យបានទាន់ពេលវេលា ។

ទទួលបានសេចក្ដីណែនាំនេះ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) ត្រូវផ្សព្វផ្សាយសេចក្ដីណែនាំនេះឱ្យបានដល់ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ។ល

ភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

**គ.ប.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

**តេព នីថា**